ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តស្វាយរៀង

ស្រុករំដួល

ឃុំជ្រុងពពេល

លេខៈ 686.........

# ដីកា

## ស្តីពី

## " ការបង្ការ និងទប់ស្កាត់អំពើហិង្សារួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង "

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ ជ្រុងពពេល ស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី...25......ខែ...11....... ឆ្នាំ២០១៦ ។
- យោងលទ្ធផលសិក្ខាសាលាស្តីពី"វិធានការរួមស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី.....25........ខែ...11............ឆ្នាំ២០១៦ ។

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និង ប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋជារួមក្នុងឃុំ ជ្រុងពពេល ដូច្នេះក្រុមប្រឹក្សាឃុំ ជ្រុងពពេល

## សម្រេច

**ប្រការ១៖** ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រីសិទ្ធិកុមារនិងបង្ការអំពើហិង្សាលើដៃគូស្និទ្ធស្នាលព្រមទាំងលើកកម្ពស់សុខុមាលភាពនិងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់ និង សុវត្ថិភាពក្នុងឃុំ ជ្រុងពពេល ទាំងមូល ។

**ប្រការ២៖** ដីកានេះមានវិសាលភាពអនុវត្តទៅលើ អ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬបង្ករការរំខាន ឬបង្កហិង្សានានារួមទាំងទៅលើដៃគូស្និទ្ធស្នាលដូចជាប្តីប្រពន្ធ សង្សា ព្រមទាំងអ្នកផលិត អ្នកលក់ផលិត ផលគ្រឿងស្រវឹងទៅឲ្យជនឬនៅទីកន្លែងមួយចំនួនក្នុងឃុំជ្រុងពពេល ដែលបានកំណត់ក្នុងដីកានេះ ។

**ប្រការ៣៖**ហាមប្រើឲ្យទិញ ឬលក់គ្រឿងស្រវឹងឲ្យក្មេងចាប់ពីអាយុ១៨ឆ្នាំចុះក្រោម ។ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី២០០០០៛(ពីរម៉ឺនរៀល) ទៅ៥០០០០៛ (ប្រាំម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។

**ប្រការ៤៖**រាល់ការផលិតឬលក់គ្រឿងស្រវឹងត្រូវមានការអនុញ្ញាត និង ចេញលិខិតដោយមេឃុំ ហើយមានការត្រួតពិនិត្យពីអ្នកជំនាញរបស់ក្រសួងសុខាភិបាល ។ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់១០០០០៛ ( មួយម៉ឺនរៀល)ទៅ ៣០០០០៛ (បីម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ក្នុងករណីពិន័យបីលើកហើយនៅមិនរាងចាលត្រូវបញ្ឈប់ការផលិតនិង ការលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ ។

**ប្រការ៥៖**អ្នកដែលប្រើប្រាស់គ្រឿងស្រវឹងហើយដើរស្រែកឡូឡា ឬ ប្រើឧបករណ៍បំពងសំឡេងរំខានដល់អ្នកដទៃចាប់ពីម៉ោង១១:០០នាទីយប់តទៅត្រូវផាកពិន័យជាទឹកប្រាក់១០០០០០រៀល(ដប់ម៉ឺនរៀល) ទៅ១៥០០០០៛(ដប់ប្រាំម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង

**ប្រការ៦៖**មិនអនុញ្ញាតអោយមានការលក់ផលិតផលគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹងគ្រប់ប្រភេទនៅ តាមបរិវេណវត្តអារាម សាលាឆទាន សាលារៀន មណ្ឌលសុខភាព សាលាឃុំ ប៉ុស្តិ៍រដ្ឋបាល។
ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់៣០០០០៛ (បីម៉ឺនរៀល)ទៅ៥០០០០៛ ( ប្រាំម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។

**ប្រការ៧៖** អ្នកប្រើប្រាស់គ្រឿងស្រវឹង ហើយបង្កហិង្សាដែលទាក់ទងផ្លូវចិត្ត និង ផ្លូវសេដ្ឋកិច្ច (ជេរប្រមាថអ្នកដទៃ , បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ) ត្រូវផាកពិន័យជាទឹកប្រាក់ពី៣០០០០៛ (បីម៉ឺនរៀល) ទៅ ៥០០០០៛ (ប្រាំម៉ឺនរៀល) ព្រមទាំងសងជាសំណងដល់ការខូចខាតសម្ភារៈ ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង។ចំពោះបទឧក្រិដ្ឋត្រូវចាត់វិធានការទៅតាមផ្លូវច្បាប់ ។

**ប្រការ៨៖** មិនត្រូវលក់ឲ្យ ឬ ទិញគ្រឿងស្រវឹង ចំពោះអ្នកដែលស្ថិតក្នុងស្ថានភាពស្រវឹងជោគជាំ ។ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី២០០០០៛ ( ពីរម៉ឺនរៀល) ទៅ ៥០០០០៛ (ប្រាំម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។ ចំពោះអ្នកបើកបរហួសល្បឿនកំណត់ក្រោមឥទ្ធិពលនៃការប្រើប្រាស់គ្រឿងស្រវឹងបើមានបញ្ហាប៉ះឬបុកអ្នកដទៃប្រជាពលរដ្ឋក្នុងឃុំទាំងមូលមានសិទ្ធិស្ទាក់ចាប់រួចបញ្ជូនទៅសមត្ថកិច្ច ។

**ប្រការ៩៖** រាល់ការផាកពិន័យ និង ការចុះត្រួតពិនិត្យជាតួនាទីរបស់ក្រុមប្រឹក្សាឃុំ និង នគរបាលប៉ុស្តិ៍រដ្ឋបាលហើយថវិកាដែលផាកបាននោះត្រូវរក្សាទុកនៅសាលាឃុំដើម្បីចាត់ចែងក្នុងការបើកវគ្គផ្សព្វផ្សាយពីផលប៉ះពាល់ការប្រើប្រាស់គ្រឿងស្រវឹង និង ចាត់ចែងក្នុងការលើកទឹកចិត្តដល់អ្នកដែលឈប់ប្រើប្រាស់គ្រឿងស្រវឹងជាស្ថាពរ ។

**ប្រការ១០៖**អជ្ញាធរមូលដ្ឋានភូមិ ឃុំ ប៉ូលីសប៉ុស្តិ៍រដ្ឋបាល គ្រូបង្រៀន បុគ្គលិកសុខាភិបាល យុវជន គណៈកម្មការអាចារ្យ និង ព្រះសង្ឃត្រូវចូលរួមផ្សព្វផ្សាយដល់ប្រជាជនក្នុងសហគមន៍ឲ្យបានជ្រួតជ្រាប

**ប្រការ១១៖** ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅឃុំជ្រុងពពេល,ថ្ងៃទី...25....ខែ...11.....ឆ្នាំ២០១៦

សំ_អឿ